# **ចូរសូម ចូររក ចូរគោះ**

អែលឌើរ រ៉សុល អិម ណិលសុន
ក្រុមនៃពួកសាវកដប់ពីរនាក់

*ពួកបរិសុទ្ធគ្រប់រូបអាចមានភាពសក្តិសមដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំមានអំណរគុណចំពោះអ្នករាល់គ្នាម្នាក់ៗជាខ្លាំង ។ ហើយខ្ញុំក៏មានអំណរគុណចំពោះអព្ភូហេតុ នៃទំនាក់ទំនងនាសម័យទំនើបនេះផងដែរ ដែលធ្វើឱ្យមនុស្សរាប់លាននាក់នៅពាសពេញពិភពលោកអាចស្តាប់ និងមើលសន្និសីទនេះ ។

បច្ចេកវិទ្យានាពេលបច្ចុប្បន្ននេះក៏ធ្វើឱ្យអ្នកប្រើប្រាស់អាចផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកបានយ៉ាងឆាប់រហ័ស តាមរយៈទូរស័ព្ទដៃផងដែរ ។ ក្នុងពេលថ្មីៗនេះ វ៉ែនឌី និងខ្ញុំ បានទៅធ្វើការនៅទ្វីបផ្សេង នៅពេលនោះយើងដឹងថាគ្រួសាររបស់យើងកំពុងទទួលបានទារកថ្មីមួយទៀត ។ យើងបានទទួលដំណឹងល្អនេះ ប៉ុន្មាននាទីបន្ទាប់ពីកំណើតនៃទារកថ្មី គឺនៅមួយចំហៀងទៀតនៃពិភពលោក ។

អ្វីដែលអស្ចារ្យជាងបច្ចេកវិជ្ជាទំនើបទៅទៀតនោះគឺ យើងមានឱកាសទទួលព័ត៌មានពីស្ថានសួគ៌ដោយផ្ទាល់ ដោយមិនចាំបាច់មានហាតវ៉ែរ សហ្វវ៉ែរ ឬត្រូវបង់សេវាកម្មប្រចាំខែនោះទេ ។ នេះគឺជាអំណោយទានមួយ ដ៏អស្ចារ្យជាងគេបំផុតដែលព្រះអម្ចាស់បានប្រទានឱ្យដល់ជីវិតរមែងស្លាប់ ។ នេះគឺជាសេចក្តីអញ្ជើញដ៏ សប្បុរសរបស់ទ្រង់ចូរ "*សូម* នោះតែងនឹងឱ្យមកអ្នក *ចូររក* នោះតែងនឹងឃើញ *ចូរគោះ* នោះតែងនឹងបើកឱ្យអ្នក" ។ [1]

ការផ្តល់ឱ្យដ៏មិនចេះចប់មិនចេះហើយនេះ គឺដើម្បីផ្តល់វិវរណៈផ្ទាល់ខ្លួនដល់កូនចៅទាំងអស់របស់ទ្រង់ ។ ស្តាប់ទៅហាក់បីដូចជាហួសពីការពិត ។ ប៉ុន្តែវាគឺជាការពិតមែន! ខ្ញុំបានទទួល និងបានឆ្លើយតបចំពោះជំនួយសួគ៌ានោះ ។ ហើយខ្ញុំបានរៀនថា ខ្ញុំត្រូវតែរួចរាល់ជានិច្ចដើម្បីទទួលជំនួយនោះ ។

ជាច្រើនឆ្នាំកន្លងទៅហើយ ខណៈដែលស្លុងទៅក្នុងកិច្ចការរៀបចំឡើងនិយាយសំរាប់សន្និសីទទូទៅ ខ្ញុំបានក្រោក ឡើងពីដំណេកដ៏លង់លក់ ដោយមានការបំផុសគំនិតយ៉ាងខ្លាំងនៅក្នុងខួរក្បាលខ្ញុំ ។ រំពេចនោះខ្ញុំបានចាប់ខ្មៅដៃ និងក្រដាសក្បែរគ្រែរបស់ខ្ញុំ ហើយសរសេរយ៉ាងលឿនតាមដែលអាចធ្វើបាន ។ ខ្ញុំបានត្រឡប់ទៅដេកវិញទាំងដឹងថា ខ្ញុំបានចាប់បានការបំផុសយ៉ាងអស្ចារ្យ ។ នៅព្រឹកបន្ទាប់ ខ្ញុំក្រឡេកមើលក្រដាសនោះ ហើយឃើញថាការសរសេរ របស់ខ្ញុំភាគច្រើនរញ្ជេរញ្ជៃ ហើយការសរសេរទាំងមូលពិតជាមើលមិនដាច់ឡើយ! ខ្ញុំនៅតែទុកខ្មៅដៃ និងក្រដាស នៅក្បែរគ្រែរបស់ខ្ញុំ ប៉ុន្តែពេលនេះខ្ញុំសរសេរដោយផ្ចិតផ្ចង់ ។

ដើម្បីទទួលបានព័ត៌មានពីស្ថានសួគ៌ មនុស្សម្នាក់ត្រូវតែមានសេចក្តីជំនឿរឹងមាំ និងបំណងប្រាថ្នាដ៏ជ្រាលជ្រៅ ។ មនុស្សម្នាក់ត្រូវតែ "សួរដោយចិត្តស្មោះស [នឹង]ដោយស្មោះអស់អំពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ ព្រះ[យេស៊ូវ]គ្រីស្ទ" ។ [2] "ដោយស្មោះអស់អំពីចិត្ត" មានន័យថាមនុស្សម្នាក់ធ្វើតាម *ដោយស្មោះអស់អំពីចិត្ត* ចំពោះទិសដៅដ៏ទេវភាពដែលបានប្រទានឱ្យ ។

តម្រូវការបន្ទាប់គឺត្រូវសិក្សាបញ្ហាទាំងឡាយដោយឧស្សាហ៍។ គំនិតនេះត្រូវបានបង្រៀនដល់ពួកអ្នកដឹកនាំ នៃសាសនាចក្រដែលបានស្តារឡើងវិញនេះ នៅពេលដែលពួកលោកត្រូវចាប់ផ្តើមរៀនពីរបៀបទទួលវិវរណៈផ្ទាល់ខ្លួនដំបូង។ ព្រះអម្ចាស់បានណែនាំដល់ពួកគេថា "យើងប្រាប់អ្នកថា អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយត្រូវសូមដល់យើង បើសិនជាការណ៍នោះត្រឹមត្រូវ បើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្តាលឱ្យទ្រូងរបស់អ្នកខ្វល់ខ្វាញ់ខាងក្នុង ដូច្នេះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ"។3

ផ្នែកមួយនៃការរៀបចំគឺត្រូវដឹង ហើយប្រតិបត្តិតាមការបង្រៀនរបស់ព្រះអម្ចាស់។ សេចក្តីពិតដ៏មិនចេះអស់របស់ទ្រង់មួយចំនួនគឺត្រូវបានអនុវត្តជាទូទៅ ដូចជាបញ្ញត្តិមិនឱ្យលួច ឬកុំសម្លាប់ និងមិនឱ្យថ្លែងទីបន្ទាល់ក្លែងក្លាយ។ ការបង្រៀន ឬបទបញ្ញត្តិផ្សេងទៀតក៏មានលក្ខណៈទូទៅផងដែរ ដូចជាការរក្សាថ្ងៃសីល ពិធីសាក្រាម៉ង់ ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

វិវរណៈមួយចំនួនទៀតត្រូវបានប្រទានឱ្យសំរាប់កាលៈទេសៈពិសេស ដូចជាណូអេ សង់ទូក ឬការចាំបាច់ចំពោះ ព្យាការីដូចជាម៉ូសេ លីហៃ និងព្រិកហាំ ដើម្បីដឹកនាំអ្នកដើរតាមរបស់ពួកគេនៅក្នុងដំណើរដ៏ពិបាក។ ការបង្កើតគំរូដ៏វែងឆ្ងាយរបស់ព្រះនៃការបង្រៀនដល់កូនចៅទ្រង់តាមរយៈព្យាការី គឺដើម្បីអះអាងដល់យើងថា ទ្រង់នឹងប្រទានពរដល់ព្យាការីម្នាក់ៗ ហើយទ្រង់នឹងប្រទានពរដល់អស់អ្នកដែលយកចិត្តទុកដាក់ស្តាប់តាម ដំបូន្មានរបស់ព្យាការី។

បំណងប្រាថ្នាក្នុងការធ្វើតាមរបស់ព្យាការី គឺតម្រូវឱ្យមានការខិតខំយ៉ាងខ្លាំង ពីព្រោះមនុស្សខាងសាច់ឈាម ស្គាល់អំពីព្រះបន្តិចបន្តួចប៉ុណ្ណោះ ហើយកាន់តែមិនសូវស្គាល់ព្យាការីរបស់ទ្រង់។ ប៉ុល បានសរសេរថាៈ " មនុស្សខាង សាច់ឈាមគេមិនទទួលសេចក្តីខាងវិញ្ញាណនៃព្រះទេៈ ពីព្រោះជាសេចក្តីល្ងីល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ" ។4 ការផ្លាស់ប្តូរពីមនុស្ស ខាងសាច់ឈាមទៅជា សិស្សដែលមានការលះបង់ គឺជាការផ្លាស់ប្តូរមួយដ៏ធំ ។5

ព្យាការីម្នាក់ផ្សេងទៀតបានបង្រៀនថាៈ "មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ ហើយមានមកតាំងពីការធ្លាក់នៃលោកអ័ដាមម្ល៉េះ ហើយនឹងនៅយ៉ាងនេះជារៀងដរាបតទៅ លើកលែងតែគេព្រមធ្វើតាម សេចក្តីទូន្មាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយសម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅជាអ្នកបរិសុទ្ធវិញ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ហើយក្លាយទៅដូចជាកូនក្មេង ងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន ពោរពេញទៅដោយសេចក្តីស្រឡាញ់ ព្រមទទួលនូវអ្វីៗទាំងអស់ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អ ដូចជាកូន ក្មេងព្រមធ្វើតាមឪពុកខ្លួនដូច្នេះ" ។6

ថ្មីៗកន្លងទៅនេះខ្ញុំបានមើលឃើញការផ្លាស់ប្តូរដ៏ធំនៅក្នុងខ្លួនបុរសម្នាក់ ដែលខ្ញុំបានជួបលើកដំបូង 10 ឆ្នាំកន្លងទៅហើយ។ គាត់បានមកសន្និសីទស្តេក នៅពេលដែលកូនប្រុសរបស់គាត់បានតែងតាំងជាសមាជិកគណៈប្រធានស្តេកថ្មី។ ឪពុកម្នាក់នេះមិនមែនជាសមាជិកនៃសាសនាចក្រទេ។ បន្ទាប់ពីកូនប្រុសរបស់គាត់បានញែកចេញ ខ្ញុំបានឱបគាត់ ហើយបានកោតសរសើរគាត់ដែលមានកូនប្រុសដ៏អស្ចារ្យយ៉ាងនេះ។ បន្ទាប់មកខ្ញុំបានប្រកាសយ៉ាង អង់អាចថាៈ "ថ្ងៃណាមួយនឹងមកដល់នៅពេលដែលអ្នកចង់ផ្សាភ្ជាប់ជាមួយកូនប្រុសម្នាក់នេះ និងភរិយារបស់អ្នកនៅក្នុងព្រះវិហារបរិសុទ្ធ។ ហើយនៅពេលដែលថ្ងៃនោះមកដល់ ខ្ញុំមានកិត្តិយសណាស់ដើម្បីធ្វើកិច្ចការផ្សាភ្ជាប់នេះសំរាប់លោក" ។

ខ្ញុំពុំបានឃើញបុរសនោះជាយូរយាមកហើយ ។ ប្រាំមួយសប្តាហ៍មុន គាត់ និងភរិយារបស់គាត់បានមកការិយាល័យរបស់ខ្ញុំ។ គាត់បានរាក់ទាក់ខ្ញុំយ៉ាងកក់ក្តៅ ហើយរៀបរាប់ពីការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលគាត់ បានទទួលការអញ្ជើញ ពីមុនរបស់ខ្ញុំ។ គាត់មិនបានធ្វើអ្វីអំពីរឿងនោះទេ រហូតដល់ក្រោយមកនៅពេលដែលគាត់ស្តាប់ពុំសូវឮ។ បន្ទាប់មកគាត់ចាប់ផ្តើមភ្ញាក់ខ្លួនដឹងថា រូបកាយរបស់គាត់មានការផ្លាស់ប្តូរ ហើយពេលវេលារស់នៅលើផែនដីរបស់គាត់មានកំណត់។ នៅទីបំផុតគាត់បានបាត់បង់ការស្តាប់ឮរបស់គាត់ទាំងស្រុង។ ហើយនៅក្នុងពេលតែមួយនេះផងដែរគាត់ បានប្រែចិត្តជឿ ហើយបានចូលរួមនៅក្នុងសាសនាចក្រ ។

អំឡុងពេលនៃការជួបសួរសុខទុក្ខរបស់យើង គាត់បានសង្ខេបពីការប្រែប្រួលទាំងស្រុងរបស់គាត់ៈ " ខ្ញុំត្រូវតែបាត់បង់ការស្តាប់ឮរបស់ខ្ញុំពីមុនខ្ញុំយកចិត្តទុកដាក់ទៅលើសារលិខិតដ៏មានសារៈសំខាន់មហិមារបស់លោក។ បន្ទាប់មកខ្ញុំចាប់ផ្តើមដឹងថា តើខ្ញុំចង់ផ្សាភ្ជាប់ជាមួយមនុស្សជាទីស្រឡាញ់របស់ខ្ញុំប៉ុណ្ណា។ ឥឡូវនេះខ្ញុំមានភាពសក្តិសម និងមានការរៀបចំ។ សូមអ្នកធ្វើពិធីផ្សាភ្ជាប់នោះបានទេ?"[7] ខ្ញុំធ្វើកិច្ចការនេះដោយកតញ្ញូតាយ៉ាងជ្រាលជ្រៅចំពោះព្រះ ។

បន្ទាប់ពីការផ្លាស់ប្រែចិត្តជឿនោះមក នោះការវែកញែកខាងវិញ្ញាណបន្ថែមទៀតអាចកើតមាន។ វិវរណៈផ្ទាល់ខ្លួនវិវត្តន៍ប្រែក្លាយទៅជាការវែកញែកខាងវិញ្ញាណ។ ពាក្យថា *វែកញែក* មានន័យថា វែង បំបែក ឬញែកចេញ ។[8] អំណោយទាននៃការវែកញែកខាងវិញ្ញាណ គឺជាអំណោយទានសួគ៌ា ។[9] វាអនុញ្ញាតឱ្យសមាជិកនៃសាសនាចក្រមើលឃើញយ៉ាងជាក់ច្បាស់ និងទទួលអារម្មណ៍ដឹងអំពីអ្វីដែលអរូបី ។

ប៊ីស្សពទាំងឡាយមានសិទ្ធទទួលអំណោយទាននោះ នៅពេលដែលពួកគេប្រឈមមុខនឹងកាតព្វកិច្ចស្វែងរកជនក្រីក្រ និងយកចិត្តទុកដាក់ចំពោះមនុស្សខ្វះខាត។ ជាមួយអំណោយទាននោះ បងប្អូនស្រីទាំងឡាយអាចមើលឃើញនិន្នាការ នៅក្នុងពិភពលោក ហើយអាចវែកញែកពីនិន្នាការដែល ទោះបីជាពេញនិម ក៏វាមិនសមរម្យ ឬមានគ្រោះថ្នាក់។ សមាជិកទាំងឡាយអាចវែកញែកដឹងផែនការដែលត្រចះត្រចង់ ហើយដុះខាត់នូវអ្វីដែលលើកតំកើង និងអត់ធ្មត់ ។

ការវែកញែក គឺបានថែងយ៉ាងច្បាស់ នៅក្នុងការបង្រៀនយ៉ាងសំខាន់ដែលប្រធាន យ៉ូហាន ថេល័រ បានផ្តល់ឱ្យជាច្រើនឆ្នាំកន្លងទៅហើយ ។[10] លោកបានបង្រៀនប្រធានស្តេក ប៊ីស្សព និងសមាជិកផ្សេងទៀតថាៈ "វាគឺជាសិទ្ធិរបស់អស់អ្នកដែលកាន់ [តំណែងនោះ] ដើម្បីទទួលយកព្រះបន្ទូលរបស់ព្រះ ស្តីពីករណីយកិច្ច ជាគណៈប្រធានរបស់ពួកគេ ដើម្បីពួកគេអាចកាន់តែមានប្រសិទ្ធភាពក្នុងការកាន់តាមគោលបំណងដ៏បរិសុទ្ធរបស់ទ្រង់។ គ្មានការហៅ ឬតំណែងណានៅក្នុងបព្វជិតភាពមានចេតនាចង់បានប្រយោជន៍ផ្ទាល់ខ្លួន សំណង និងកិត្តិនាម សម្រាប់សំណាក់អស់អ្នកដែលកាន់នោះឡើយ ប៉ុន្តែគឺដើម្បីបំពេញគោលបំណងរបស់ព្រះវរបិតាសួគ៌ និងកសាងនគររបស់ព្រះ នៅលើផែនដីវិញ។ ...យើង...ស្វែងរកដើម្បីយល់ពីគោលបំណងរបស់ព្រះ ហើយបន្ទាប់មកប្រកាន់ខ្ជាប់តាមព្រះបន្ទូលនោះ និងមើលឃើញថាវាបានប្រកាន់ខ្ជាប់ដោយអស់អ្នកដែល យើងទទួលខុសត្រូវលើពួកគេ" ។[11]

សំរាប់អ្នកម្នាក់ៗដើម្បីទទួលវិវរណៈ ទៅតាមសេចក្តីត្រូវការចាំបាច់ និងពិសេសផ្ទាល់ខ្លួន ក្នុងនោះមានគោលការណ៍ជាក់លាក់មួយចំនួន។ ព្រះអម្ចាស់កោះហៅអ្នកឱ្យអភិវឌ្ឍ "សេចក្តីជំនឿ សេចក្តីសង្ឃឹម សេចក្តីសប្បុរស និងសេចក្តីស្រឡាញ់ ដោយភ្នែកស្មោះទាំងស្រុង ចំពោះសិរីល្អនៃព្រះ"។ បន្ទាប់មកព្រមជាមួយនឹង " សេចក្តីជំនឿ គុណធម៌ ដឹរិះ សេចក្តីអត់សង្កត់ សេចក្តីអត់ធន់

សេចក្តីរាប់អានគ្នាជាបងប្អូន សេចក្តីកោតខ្លាតដល់ព្រះ សេចក្តីសប្បុរស សេចក្តីទាបរាបសា [និង] សេចក្តីឧស្សាហ៍" ដ៏រឹងមារបស់អ្នក នោះអ្នករាល់គ្នាអាច*សូម* ហើយអ្នករាល់គ្នានឹងបានទទួល *អ្នករាល់គ្នាអាចគោះ* ហើយតែងនឹងបើកឱ្យអ្នករាល់គ្នា។12

វិវរណៈពីព្រះគឺតែងតែដើរទន្ទឹមគ្នាជាមួយនឹងក្រឹត្យវិន័យដ៏អស់កល្បជានិច្ចរបស់ទ្រង់។ វាមិនដែលផ្ទុយពីគោលលទ្ធិរបស់ទ្រង់នោះទេ។ លទ្ធភាពទទួលវិវរណៈ គឺមានជំនួយពីការរៀបចំដ៏ទេវភាពមកពីអាទិទេព។ ព្រះអម្ចាស់បានផ្តល់សេចក្តីណែនាំនេះថា:

"យើងជាព្រះអម្ចាស់មានសេចក្តីមេត្តាករុណា និងអាណិតអាសូរដល់អស់អ្នកណាដែលកោតខ្លាចដល់យើង ហើយសព្វព្រះហឫទ័យនឹងឱ្យកិត្តិយសដល់អស់អ្នកណាដែល បំរើយើងដោយនូវសេចក្តីសុចរិត និងដោយនូវសេចក្តីពិត រហូតដល់ចុងបំផុត។

"នឹងមានភាពមហិមាណាស់រង្វាន់របស់ពួកគេ ហើយភាពអស់កល្បជានិច្ចទៅជាសិរីល្អរបស់ពួកគេ។

"...ចំពោះពួកគេ នោះយើងនឹងបើកសំដែងអស់ទាំងសេចក្តីអាថ៌កំបាំង [ហើយ]យើងនឹងធ្វើឱ្យពួកគេស្គាល់នូវបំណងព្រះហឫទ័យរបស់យើងអំពីគ្រប់ទាំងអស់ ដែលទាក់ទងនឹងនគររបស់យើង"។13

វិវរណៈមិនចាំបាច់មកម្តងទាំងអស់នោះទេ។ វាប្រហែលជាបន្ថែមបន្តិចម្តងៗ។ "ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានបន្ទូលថាដូច្នេះ យើងនឹងប្រទានដល់កូនចៅមនុស្សមួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ ឯណេះបន្តិច ឯណោះបន្តិច នេះមានមានពរហើយ ដល់អស់អ្នកណាដែលប្រុងស្តាប់តាមសិក្ខាបទទាំងឡាយរបស់យើង ហើយផ្ទៀងត្រចៀកស្តាប់ពាក្យទូន្មានរបស់យើង ត្បិតពួកគេនឹងមានប្រាជ្ញា ត្បិតចំពោះអ្នកណាដែលបានទទួល នោះយើងនឹងឱ្យថែមទៀត"។14 សេចក្តីអត់ធ្មត់ និងសេចក្តីខ្ជាប់ខ្ជួន គឺជាផ្នែកមួយនៃការរីកចំរើនដ៏អស់កល្បជានិច្ចរបស់យើង។

ព្យាការីបានពិពណ៌នាអំពីអ្វីដែលពួកគេទទួលអារម្មណ៍ អំឡុងពេលកំពុងទទួលវិវរណៈ។ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានរាយការណ៍ថា: "ស្បៃត្រូវបានបើកពីគំនិតរបស់ពួកយើង ហើយភ្នែកនៃយោបល់របស់ពួកយើងត្រូវបានបើក ឡើង"។15 ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានសរសេរថា "នៅពេលខ្ញុំកំពុងតែពិចារណាពីការណ៍ទាំងនេះ ដែលបានសរសេរទុក នោះស្រាប់តែភ្នែកនៃយោបល់របស់ខ្ញុំត្រូវបានបើកហើយព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើ ខ្ញុំ"។16

ពួកបរិសុទ្ធគ្រប់រូបអាចមានភាពសក្តិសមដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន។ ការអញ្ជើញឱ្យ ចូរសូម ចូររក និង ចូរគោះចំពោះសេចក្តីណែនាំដ៏ទេវភាពកើតមានពីព្រោះព្រះ និងព្រះយេស៊ូវ ជាព្រះគ្រីស្ទ មានព្រះជន្មរស់។ មានវិវរណៈពីព្រោះ នេះជាសាសនាចក្រដ៏សកម្មរបស់ទ្រង់។17 ហើយយើងនឹងបានទទួលពរជ័យ នាពេលបច្ចុប្បន្ននេះ ដោយសារប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការីដែលនៅរស់។ សូមយើងស្តាប់តាម និងយកចិត្តទុកដាក់ចំពោះដំបូន្មានដែលលោកបានព្យាករណ៍ នេះគឺជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. ម៉ាថាយ 7:7 លូកា 11:9 ជាការបញ្ជាក់បន្ថែម ។ សូមមើលផងដែរ នីហ្វៃទី 3 14:7 Joseph Smith Translation ម៉ាថាយ 7:12 នៅក្នុង Bible appendix ។

2. មរ៉ូណៃ 10:4 ។

3. គ និង ស 9:8 ។

4. កូនរិនថូសទី 1 2:14 ។

5. សូមមើល ម៉ូសាយ 5:2 អាល់ម៉ា 5:12--14 ។

6. ម៉ូសាយ 3:19 ។

7. ការផ្លាស់ប្រែចិត្តជឿដូច្នេះគឺពេញលេញ ។ John Newton (1725--1807) ឧទាហរណ៍ បានធ្វើឱ្យទម្រង់នៃជីវិតរបស់គាត់មានការផ្លាស់ប្តូរពីអ្នកជួញកម្មករទៅជាសិស្សដែលមានការលះបង់របស់ព្រះអម្ចាស់ សេចក្តីសង្ខេបអំពីការផ្លាស់ប្រែចិត្តជឿរបស់គាត់នៅពេលដែលគាត់សរសេរថា: "ព្រះគុណរបស់ទ្រង់អស្ចារ្យខ្លាំងណាស់! (ឱព្រះបន្ទូលដ៏ផ្អែមល្ហែម)/ ដែលបានជួយសង្គ្រោះបុរសទុច្ចរិតដូចខ្ញុំ!/មានម្តងនោះខ្ញុំបានវង្វេង ប៉ុន្តែឥឡូវនេះខ្ញុំបានរកឃើញ/ខ្ញុំធ្លាប់ខ្វាក់ ឥឡូវនេះបានមើលឃើញ" ("Amazing Grace" *Olney Hymns* [ឆ្នាំ 1779] ទំព័រ 41 ) ។

8. ពាក្យ *វែកញែក* ជាភាសាអង់គ្លេស (discern) ដកស្រង់ចេញពីភាសាឡាតាំង *discernere (ស្គាល់)* មានន័យថា "ការញែកចេញ ឬការស្គាល់ច្បាស់ចំពោះអ្វីមួយ" បុព្វបទឡាតាំង *dis* មានន័យថា "ញែកចេញ" ហើយពាក្យបន្ទាប់ *cernere* មានន័យថា "រែង" ។ សូមមើល *Merriam-Webster's Collegiate Dictionary* ការបោះពុម្ពលើកទី 11 (ឆ្នាំ 2003) "discern" ។

9. សូមមើល គ និង ស 46:23, 26--27 ។

10. បន្ទាប់ពីមរណភាពរបស់ប្រធាន ព្រិកហាំ យ៉ង់ នៅក្នុងឆ្នាំ 1877 កិច្ចការរបស់សាសនាចក្របាន ដឹកនាំដោយ ក្រុមសាវកទាំងដប់ពីរនាក់ ។ ក្រុមសាវកបានបន្តដឹកនាំបណ្តោះអាសន្នរហូតដល់ឆ្នាំ 1880 រហូតដល់គណៈប្រធានទីមួយបានរៀបចំឡើង ។ យ៉ូហាន ថេលើរ គឺជាប្រធាននៃក្រុមសាវកទាំងដប់ពីរនាក់នាពេលនោះ ខណៈដែលដំបូន្មាននេះបានផ្តល់ឱ្យនៅថ្ងៃទី 23 ខែ កុម្ភៈ ឆ្នាំ 1878 ។

11. *Messages of the First Presidency of The Church of Jesus Christ of Latter-day Saints* compiled វ៉ុល 6 (ឆ្នាំ 1965--75) 2: 307 ចងក្រងដោយ James R. Clark ។

12. គ. និង ស. 4:5--6 ជាការបញ្ជាក់បន្ថែម ។ សូមមើល ខ. 7 ផងដែរ ។

13. គ និង ស 76:5--7 ។

14. នីហ្វៃទី 2 28:30 ។

15. គ និង ស 110:1 ។

16. គ. និង ស. 138:11 ។ ក្រោយមកមានវិវរណៈអំពីការប្រកាសដំណឹងល្អទៅកាន់អស់អ្នកដែលទទួលមរណភាព ហើយគ្មានឱកាសឮដំណឹងល្អនៅក្នុងជីវិតរមែងស្លាប់នេះទេ (សូមមើល ខ. 29--37 ) ។

17. សូមមើល គ. និង ស. 1:30 ។